**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រកាសជ្រើសរើសបេក្ខភាពសម្រាប់មុខតំណែងជាប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិនៃអគ្គនាយកដ្ឋានកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់មន្ត្រីរាជការក្រោមឱវាទទាំងអស់ ជ្រាបថា ក្រសួងប្រកាសជ្រើសរើសបេក្ខភាពសម្រាប់ទទួលមុខតំណែងជា "ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិនៃអគ្គនាយកដ្ឋានកសិកម្ម" ចាប់ពីពេលនេះតទៅ។ បេក្ខជនដែលមានបំណងចង់ដាក់ពាក្យស្នើសុំទទួលមុខតំណែងនេះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ | ៖ ជាមន្ត្រីក្របខ័ណ្ឌ "ក" នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២. | កម្រិតសញ្ញាបត្រ | ៖ ចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ដោយមានជំនាញផ្នែករដ្ឋបាលសាធារណៈ ឬជំនាញចាំបាច់ពាក់ព័ន្ធ |
| ៣. | ចំណេះដឹងទូទៅ | ៖ ចេះភាសាអង់គ្លេស និងអាចប្រើប្រាស់ព័ត៌មានវិទ្យាបាន |
| ៤. | អតីតភាពការងារ | ៖ យ៉ាងតិច ០៥ឆ្នាំឡើងទៅ គិតចាប់ពីកាលបរិច្ឆេទតាំងស៊ប់ |
| ៥. | មុខតំណែងបច្ចុប្បន្ន | ៖ ជាប្រធានការិយាល័យ អនុប្រធាននាយកដ្ឋាន ឬប្រធាននាយកដ្ឋាន |
| ៦. | ឯកសារពាក់ព័ន្ធ | ៖ ពាក្យស្នើសុំ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីមូលហេតុនៃការស្នើសុំមុខតំណែងនេះ ព្រមទាំងចក្ខុវិស័យសម្រាប់នាយកដ្ឋាន ប្រវត្តិរូបផ្ទាល់ខ្លួន សញ្ញាបត្រថតចម្លង និងឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។ |

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមលើកទឹកចិត្តដល់មន្ត្រីទាំងអស់ដែលបំពេញបាននូវលក្ខខណ្ឌខាងលើ ឱ្យមកដាក់ពាក្យនៅនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ចាប់ពីពេលនេះតទៅរហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ត្រឹមវេលាម៉ោង០៥:៣០នាទីល្ងាច។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋាន តាមរយៈលេខទូរស័ព្ទ ៖ ០១២ ៥៣៧ ៣៧៣ ក្នុងម៉ោង និងថ្ងៃធ្វើការ។

ថ្ងៃ ... ខែ ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ តុលា ឆ្នាំ២០២៣

អគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320